# ព្រះពុទ្ធរូបសម័យផ្សេងៗ

## *ស្រង់ពីកម្ពុជសុរិយា ព.ស.២៤៨២ គ.ស.១៩៤០*

*កាលពីខែសេបតមប្រឺ (កញ្ញា) គ.ស.១៩៣៨ នៅស្រុកប្រ៊ុកសែល ជាទីក្រុងនៃប្រទេសបេលស៊ិក ស្រុកនេះជាស្រុកតូច តាំងនៅខាងជើងស្រុកបារាំង។ ស្រុកនេះហើយជាទីប្រជុំដ៏សំខាន់មួយ ដែលមានការមករួបរួមប្រជុំគ្នានៃបណ្ដាបុគ្គលគ្រប់ៗប្រទេសក្នុងលោក ដើម្បីពិគ្រោះការងារជាមួយគ្នាអំពីប្រស្នាផ្សេងៗ ដែលទាក់ទងនឹងចំណែកទិសខាងកើត។*

*មានអ្នកប្រាជ្ញបារាំងសែសម្នាក់ឈ្មោះលោក* **ហ្វីយ៉ូអូសាត់** *បានពោលថ្លែងអំពីកិច្ចការរបស់អ្នកប្រាជ្ញ១រូប ប៉ែកខាងព្រះពុទ្ធសាសនាលទ្ធិមហាយានឈ្មោះ* **នាគាជុន** *ជាអ្នកប្រាជ្ញល្បីល្បាញ លោកអ្នកប្រាជ្ញនេះបានតែងតម្រាពេទ្យសាស្ត្រនិងតម្រាញែកធាតុ ផ្សំធាតុ ជាភាសាសំស្ក្រឹត ដែលគេអាចនាំទៅប្រៀបផ្ទឹមនឹងអ្នកប្រាជ្ញ១រូប នៅខាងទក្សិណទិសនៃស្រុកឥណ្ឌា “អយស្តូរៈ” ជាអ្នករៀបចំតែងគម្ពីរពេទ្យសាស្ត្រនិងគម្ពីរញែកធាតុផ្សំ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងស្រុកសៀមនិងស្រុកខ្មែរកាលពីជាន់ដើម។*

*លោកអ្នកប្រាជ្ញទាំងពីររូបនេះ បានតែងគម្ពីរ មានសេចក្ដីជាគោលសំខាន់ៗដូចគ្នាអំពីវិជ្ជាចិត្តសាស្ត្រនិងវិទ្យាសាស្ត្រនៃប្រទេសឥណ្ឌា ហើយគម្ពីរទាំងពីរនេះមិនមានរឿងរ៉ាវខាងសាសនាលាយសោះឡើយ។*

*មានជនជាតិអង់គ្លេសម្នាក់ឈ្មោះ* **ឡឺម៉ៃ** *ដែលធ្លាប់នៅស្រុកសៀមជាវេលាយូរ បាននិយាយអំពីពង្សាវតារនៅសម័យផ្សេងៗនៃស្រុកសៀមនេះ ដែលលោក* **ឡឺម៉ៃ** *បានឃើញគ្រឿងចម្លាក់រចនាផ្សេងៗ ដែលមាននៅក្នុងស្រុក ហើយមានប្រយោជន៍ដល់អ្នកមើលរឿងនេះទួទៅក្នុងស្រុកខ្មែរ។ ឯសេចក្ដីតទៅនេះ ជាសេចក្ដីសង្ខេបខ្លីៗទេ។*

**១–សម័យមុនពុទ្ធសករាជ៩៤៣-១៥៤៣** *–បែបចម្លាក់រចនាជាន់បុរាណច្រើនជាងគេ ដែលមាននៅស្រុកសៀមនោះជាចម្លាក់បែបមន។ ពួកមននេះមកអំពីប្រទេសភូមាក្រោម (Basse Birmanic) កំណើតដើមនៅមាត់សមុទ្រស្រុកឥណ្ឌាខាង*

កើត។ ក្បាច់រចនារបស់មននេះសុទ្ធតែមានគិនភាគបែបឥណ្ឌា តាំងអំពីសម័យនៃពុទ្ធសករាជ៨៤៣ដល់៩៤៣ ក្រោយមកទើបគេស្គាល់ព្រះនាមនៃវង្សស្តេចនេះ តាំងអំពីកាលនៅស្រុកឥណ្ឌា គឺក្នុងសម័យ "ក្សត្រគុប្តៈ" នៅប្រទេសប៉ែកខាងជើង។

**២–សម័យខ្មែរ ពុទ្ធសករាជ១៥៤៣ ដល់ពុទ្ធសករាជ១៧៩៣** –តាំងពីពុទ្ធសករាជ១២៤៣មក ពួកខ្មែរបានវាតឫទ្ធិអំណាចឱ្យរីកចេញទៅ ក្រោយដែលបានតាំងក្រុងនៅទីក្រុងអង្គរប្រទេសកម្ពុជា។ កាលក្នុងពុទ្ធសករាជ១៥៤៣ ស្រុកសៀមកណ្តាលនៅក្នុងអំណាចមហាអាណាចក្រខ្មែរនៅឡើយ។ មានឧបរាជមួយអង្គគង់នៅក្រុងលុពបូរីជាទីប្រជុំជនបុរាណប្រកាន់តាមអារ្យធម៌របស់មន ក្រុងលុពបូរីនេះនៅខាងជើងក្រុងបាងកក ចម្ងាយ៨០មីល (៨០ miles ខ្នាតរបស់អង់គ្លេសមួយយ៉ាង អានថាម៉ៃក្នុង១ម៉ៃត្រ ១៥០០ម៉ែត្រ)។ នៅទីនោះមានសាលាបង្រៀនចម្លាក់បែបខ្មែរ១យ៉ាង ប៉ុន្តែមានបែបភាពប្លែកជ្រុងពីក្បាច់ដែលមាននៅក្នុងស្រុកខ្មែរ។

បែបភាពព្រះពុទ្ធរូបខ្មែរមានទ្រង់ទ្រាយជាភេទបុរស ឃើញស្តែងជាងព្រះពុទ្ធរូបដែលធ្វើដោយស្នាដៃមន។ ពួកខ្មែរច្រើនប្រើដីពេជ្រនិងសំរឹទ្ធិសាងព្រះ ប៉ុន្តែរូបធ្វើពីសំរឹទ្ធិធ្លាប់មានតែព្រះអង្គតូចៗ ហើយតម្កល់ទុកបូជានៅផ្ទះ។

**៣–សម័យធៀងសែន ព.ស.១៦៤៣ដល់១៧៤៣** –តាំងអំពីពុទ្ធសករាជ១៣៩៣ នោះពួកថៃ (សៀម) មានលំនៅដើម (ស្រុកកំណើត) នៅស្រុកចិនខាងត្បូង ហើយមានតាំងស្រុកទេសថ្មីនៅស្រុកលាវ-សៀមខាងជើង កាលពីព.ស.១៦០០ នោះមហាក្សត្រជាតិភូមាព្រះនាម **អនុរុទ្ធមហារាជទី១** ទ្រង់មានស្ពានមេត្រីនឹងស្តេចព្រះនាម បលៈ ស្រុកឥណ្ឌា នៅខេត្តពិហារ ក្សត្រភូមាអង្គនេះទ្រង់បានព្រះពុទ្ធរូបបែបថ្មី១អង្គ នាំមកតម្កល់ទុកនៅប្រទេសភូមា ហើយវេលានោះនៅខាងជើងស្រុកសៀម ក្នុងតំបន់ដែនធៀងសែននោះ មានរូបសំរឹទ្ធិជាចំនួនច្រើន ដែលគេបានកសាងឡើងក្នុងសម័យនោះ។

**៤–សម័យសុខោទ័យ ប្រហែលពីព.ស.១៧៤៣ដល់ព.ស.១៨៤៣** –គឺកាលពីព.ស.១៧៩៣ ដែលពួកថៃ (សៀម) តាំងប្រទេសអាណាចក្រនៅស្រុកហៅថា សុខោទ័យនិងសួគ៌ាលោក (សៀមអានថា ស្វ័នខៈលោក) មួយទៀត ទុកដូច

ជាទីក្រុងដែរ។ ឯបែបសិប្បកម្មក្នុងសម័យនោះ បានទទួលបែបភាពថ្មីដែលបានមក ពីកោះលង្កា ហើយបែបដែនព្រះពុទ្ធរូបនេះ ក្លាយទៅជាបែបសិប្បកម្មយ៉ាងវិចិត្រជា របស់សៀម ដែលប្លែកយ៉ាងស្រឡះពីបែបខ្មែរ ដោយមានរង្វង់ព្រះភ័ក្ត្រទម្រង់ពង ក្រពើមានព្រះភូមោ (ចិញ្ចើម) កោងដូចជាវង់ធ្នូ ហើយមានព្រះអាការជាគ្រឿងសម្ដែង ភាពបែបដែនព្រះពុទ្ធរូប។

អស់ពួកលោកដែលដើរប្រកាសសាសនា បានដើរផ្សាយបែបសិល្បកម្មពុទ្ធ សាសនាថ្មីនេះចូលទៅស្រុកសៀម តាំងអំពីខាងជើងទៅខាងត្បូង។

៥–សម័យអ៊ូថង អំណាចខ្មែរនិងសៀម ប្រហែលជាក្នុងព.ស.១៧៤៣ ដល់១៨៤៣ –ក្នុងចំណែកដែនលុពបូរី មានពេលខ្លះគង់ទ្រង់នៅមិនធ្លាក់នៅក្នុង អំណាចស្រុកសុខោទ័យ ហើយក្នុងសម័យនោះ ទុកដូចជាឈ្មោះស្រុក១ ដែលនៅ ខាងលិចស្រុកអយុធ្យា។ បណ្ដារូបដែលធ្វើអំពីសំរឹទ្ធិ ក៏ផ្ដើមកើតមានឡើងតាមបែប ដែនខ្មែរ ច្រើនជាងបែបជារបស់សៀម ប៉ុន្តែតបន្តិចៗមក គេក៏កែប្រែទៅតាមគំនិត យោបល់ជាបែបសៀមវិញ។

៦–សម័យសៀម អយុធ្យា ពីព.ស.១៦៩៣ ប្រហែលដល់នៅព.ស. ២១៤៣

ក្នុងព.ស.១៨៩៣ ក្សត្រនៃស្រុកអ៊ូថង បានកតាំងទីក្រុងថ្មីនៅស្រុកអយុធ្យា ហើយភ្ជាប់ទាំងស្រុកសុខោទ័យ (មកជាចំណុះផង)។ ការចម្លាក់លើផ្ទាំងថ្មនៅស្រុក លុពបូរីក៏នៅមាននៅឡើយ ប៉ុន្តែបែបរចនាយ៉ាងល្អៗជាច្រើនអំពីដើមរលត់រលាយ ទៅក៏ពិតមែន តែបានឱ្យកំណើតដល់បែបសិល្បកម្មទំនើបថ្មីជារបស់សម្រាប់ជាតិ ដោយបង្កើតសាលាបង្រៀនដែលមានឈ្មោះថា សាលាអយុធ្យាឡើង។

អំណាចបែបដែនខ្មែរ នៅមានជាប់ជិតនៅនឹងគ្រឿងលម្អនៃគ្រឿងកសាងនឹង រូបផ្សេងៗខ្លះ ហើយមានរូបសំរឹទ្ធិជាច្រើននិងរូបធ្វើពីឈើក៏មានច្រើនដែរ។

លោក គារិតវ៉ាល់ ដែលជាអ្នកគាស់កកាយរុករកក្នុងស្រុកម៉ាឡាយូ បាន ផ្ញើសេចក្ដីរាយការណ៍មួយទៅជូនក្រុមជំនុំនានាជាតិ ចំណែកចុងបូព៌ាប្រទេសពិនិត្យ មើល នោះមានសេចក្ដីថា គេបានរកឃើញរឿងរ៉ាវខាងពុទ្ធសាសនា ដែលធ្លាក់ទុក

នៅទីងសិលាចារឹកជាន់ចាស់និងបល្ល័ង្កព្រះដែលគេខំពិនិត្យមើលនៅវេលានេះ នៅត្រង់កន្លែងនេះដើម្បីឱ្យបានដឹងថា បណ្តាបោរាណវត្ថុផ្សេងៗ (ដែលជាសម្បត្តិពុទ្ធសាសនា) ដែលគេបានរកឃើញតើនៅក្នុងសម័យណា។

ស្រាវជ្រាវដោយៈ ថាច់ សុតឹម